# អរិយធម៌ Gandhara

Gandhara គឺជាឈ្មោះរដ្ឋបុរាណ និងអរិយធម៌ដ៏ល្បីល្បាញមួយដែលបច្ចុប្បន្នស្ថិតនៅភាគពាយ័ព្យនៃប្រទេសប៉ាគីស្ថាន និងអាហ្វហ្គានីស្ថាន ហើយមានព្រំប្រទល់ខាងលិចជាប់នឹងជួរភ្នំគ្រុស និងខាងជើងជាប់នឹងជើងភ្នំហិម៉ាល័យ។ តាមរយៈសំណង់ស្ថាបត្យកម្ម សំណល់បុរាណវិទ្យា និងជាពិសេស វត្ថុសិល្បៈ នៃ Gandhara មានអាយុកាលប្រមាណជាង២០០០ឆ្នាំ (រូបលេខ១)។[១]

Gandhara គឺជាតំបន់គោរពប្រតិបត្តិព្រះពុទ្ធសាសនា ប៉ុន្តែក្រោយមកនៅឆ្នាំ៣៣០ មុនគ.ស. Alexander the great បានគ្រប់គ្រងលើតំបន់Gandharaនេះ ហើយឥទ្ធិពលនៃអរិយធម៌ក្រិចក៏បានជ្រៀបចូលក្នុងតំបន់នេះយ៉ាងខ្លាំង ដោយបានបង្កើតទៅជាសិល្បៈ និងវប្បធម៌មួយដែលហៅថា Greco-Buddhist ឬ Indo-Greek (ពុទ្ធសាសនាបែបក្រិច)។[២]

Gandhara ត្រូវបានអ្នកស្រាវជ្រាវជាច្រើនហៅថា ជាសាលានៃសិល្បៈ (Gandhara School of Art) ឬ ហៅបានថាអរិយធម៌ក្រិចរួមនឹងឥណ្ឌា។ Gandharaគឺជាតំបន់នៃសាសនា សិល្បៈ រវាងក្រិច និងឥណ្ឌា ហើយក៏ជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏រីកចម្រើនតាមបណ្ដោយផ្លូវសូត្រដែលតភ្ជាប់ប្រទេសចិន អាស៊ីខាងត្បូង និងមេឌីទែរ៉ាណេ។[៣] នៅក្នុងប្រវត្តិសាស្ត្រនៃអរិយធម៌ Gandhara ឃើញមានការឈ្លានពានពីសំណាកអាណាចក្រផ្សេងៗជាច្រើនរួមមាន ក្រិច ផាធៀន គូសាន និង ពែក្ស ជាដើម។[៤]

យើងដឹងហើយថា ព្រះពុទ្ធសាសនា គឺកើតឡើងនៅខាងជើងប្រទេសឥណ្ឌារហូតដល់តំបន់ Gandhara ប៉ុន្តែសិល្បៈដែលបង្ហាញអំពីការគោរពដល់ព្រះពុទ្ធសាសនា

---

[១] Falser_2018_Gandhara_Orientalism_Global_Art_History_Transculturality_

[២] https://www.metmuseum.org/toah/hd/gand/hd_gand.htm

[៣] https://www.metmuseum.org/art/metpublications/The_Art_of_Gandhara_in_The_Metropolitan_Museum_of_Art

[៤] The_Art_of_Gandhara_in_The_Metropolitan_Museum_of_Art

(symbolic of Buddha) ក្នុងពេលនោះ គឺគោរពដល់ រូបដើមពោធិ៍ កង់ច័ក្រ និងរូបចេតិយជាដើម ប៉ុន្តែពុំទាន់ឃើញមានធ្លាក់ ជារូបមនុស្សឡើងនោះទេ។ ការលេចឡើងដំបូងបំផុតនូវរូបព្រះពុទ្ធជាទម្រង់មនុស្សដែលហៅថា Buddha historic គឺស្ថិតនៅក្នុងសិល្បៈ Gandhara នេះហើយដែលអ្នកស្រាវជាវបានហៅ Gandhara ថាជាសាលានៃសិល្បៈ។[៥] បើយើងសង្កេតលើទម្រង់ព្រះភក្ត្រនៃរូបព្រះពុទ្ធក្នុងអរិយធម៌នេះ គឺសឹងតែដូចទៅនឹងទម្រង់មុខពួកក្រិចដែលហៅថា Greco-Buddhist។ ភាគច្រើននៃពុទ្ធរូបក្នុងសិល្បៈ Gandhara គឺទម្រង់ព្រះពោធិសត្វក្នុងនិកាយមហាយាន។ សិល្បៈទាំងនោះបានអភិវឌ្ឍខ្លាំងនៅក្នុងសម័យកាល គូសាន[៦] (រូបលេខ២-៣)។

តាក់ស៊ីឡា (Taxila) ត្រូវបានគេស្គាល់ថាជាទីក្រុង និងមជ្ឈមណ្ឌលព្រះពុទ្ធសាសនាដ៏ធំនៅក្នុងសម័យ Gandhara។[៧] បច្ចុប្បន្នទីក្រុងនេះស្ថិតនៅក្នុងខេត្ត Punjab ប្រទេសប៉ាគីស្ថាន ហើយក៏បានចុះបញ្ជីក្នុងបេតិកភណ្ឌពិភពលោកដែរ។ នៅទីក្រុងនេះឃើញមានសំណង់ព្រះពុទ្ធសាសនាជាច្រើនរួមមានដូចជា ព្រះវិហារ ចេតិយ និងពុទ្ធបដិមាផ្សេងៗដែលសល់តាំងពីសម័យ Gandhara (រូបលេខ២)។

ពល់ព័ត៌មានដែលបានរៀបរាប់ខាងលើ គឺបង្ហាញថារដ្ឋនៃអរិយធម៌នេះចាប់មានឥទ្ធិពលនៅពាក់កណ្តាលស.វ.ទី៥មុនគ.ស. រហូតដល់ស.វ.ទី២ នៃគ.ស.។ សិល្បៈ នៃអរិយធម៌ Gandhara នេះហើយដែលបង្ហាញរូបព្រះពុទ្ធជាទម្រង់មនុស្ស ដែលយើងបានឃើញពុទ្ធបដិមាទាំងនោះនៅក្នុងទីក្រុង តាក់ស៊ីឡា និងនៅតាមសាមន្ទីរល្បីផ្សេងៗ។ ពុទ្ធបដិមាជាច្រើនៗត្រូវបាននាំចេញពីតំបន់ Gandhara ទៅបណ្តាសារមន្ទីរនៅបរទេសផ្សេងៗ ជាពិសេស នៅសារមន្ទីរ ហ្គីមេ (Guimet) ក្នុងប្រទេសបារាំង ប្រមាណជាង ២០០រូប ក្នុងនោះក៏មានយកពីទីក្រុង តាក់ស៊ីឡា[៨] និងនៅសារមន្ទីរ The Metropolitan Museum of Art នៅសហរដ្ឋអាមេរិកជាដើម។ រូបទាំងនោះត្រូវបានដាក់តាំងបង្ហាញរហូតដល់សព្វថ្ងៃនេះ (រូបលេខ៥)។

---

[៥] https://www.guimet.fr/collections/-pakistan/tete-de-bodhisattva/

[៦] https://www.khanacademy.org.

[៧] https://whc.unesco.org/en/list/139

[៨] https://www.guimet.fr/sites/site_gandhara/01-presentation.html

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីនៃតំបន់ Gandhara

ប្រភព៖ Falser



រូបលេខ២៖ ទម្រង់មុខពុទ្ធបដិមា ក្រិច ឥណ្ឌា

ប្រភព៖https://www.guimet.fr

អត្ថបទដោយ៖ អេង តុលា



រូបលេខ៣៖ ពុទ្ធបដិមាដំបូងៗក្នុងសិល្បៈ Gandhara( ក្រិច ឥណ្ឌា )

ប្រភព៖ https://www.metmuseum.org

អត្ថបទដោយ៖ អេង តុលា





រូបលេខ២៖ សំណង់ពុទ្ធសាសនានៅទីក្រុង តាក់ស៊ីឡា

ប្រភព៖ www.news.cgtn.com

អត្ថបទដោយ៖ អេង តុលា





រូបលេខ៥៖ ពុទ្ធបដិមាក្នុងសិល្ប: Gandhara

តាំងបង្ហាញនៅក្នុងសារមន្ទីរ ហ្គីមេ

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

Falser_2018_Gandhara_Orientalism_Global_Art_History_Transculturality_
https://www.metmuseum.org/toah/hd/gand/hd_gand.htm

https://www.metmuseum.org/art/metpublications/The_Art_of_Gandhara_in_The_Metropolitan_Museum_of_Art

https://www.guimet.fr/collections/-pakistan/tete-de-bodhisattva/

https://www.khanacademy.org.

https://whc.unesco.org/en/list/139

https://www.guimet.fr/sites/site_gandhara/01-presentation.html

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION